## ការរើសអើងពូជសាសន៍ (Apartheid)

វាជាបទឧក្រិដ្ឋ កើតចេញពីគោលនយោបាយសង្គមរើសអើងពូជសាសន៍ (race)។ ទង្វើនេះ បង្កនូវការឈឺចាប់ធ្ងន់ធ្ងរ។

អំពើនេះ ត្រូវបានចែងហាមឃាត់ ដោយអនុសញ្ញាបង្ក្រាប និងដាក់ទោសលើអំពី Apartheid (Convention on the Suppression and Punishment of the Crime of Apartheid) ដែលផ្តោតលើជាសំខាន់ ប្រព័ន្ធដឹកនាំប្រទេសអាហ្វ្រិកខាងត្បូងនាពេលនោះ។ មាត្រា I(1) នៃអនុសញ្ញាចែងថា apartheid ជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) ក្នុងន័យនេះ វាឆ្លុះថាមានការវាយប្រហារទូទៅ ឬខ្សែសង្វាក់ ដែលជាធាតុផ្សំរួម (chapeau elements)។

បទល្មើសនេះ ត្រូវបានចែង ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងលក្ខន្តិកៈនៃ ICC ដែលជាអំពើអមនុស្សធម៌ដទៃទៀត។ វាត្រូវបានផ្តល់ន័យថា៖ ប្រព្រឹត្តក្នុងបរិបទនៃប្រព័ន្ធជាស្ថាប័ននៃការបង្ក្រាប និង គ្រប់គ្រងដោយក្រុមពូជសាសន៍មួយទៀត និងប្រព្រឹត្តជាមួយចេតនាក្នុងការរក្សារបបនោះ (មាត្រា ៧(២.h) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 245-246)។